អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ០៥៨-សណ-១៧ អអក

ភ្នំពេញ, ថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្តីពីការពិគ្រោះយោបល់សាធារណៈលើសេចក្តីព្រាងអាជ្ញាបណ្ណរបស់ ក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅភូមិ ផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឲ្យបានជ្រាបថា អនុវត្តតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងនឹងចេញអាជ្ញាបណ្ណឲ្យក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ដែលមានប្រកាសអនុញ្ញាតពីក្រសួងរ៉ែ និងថាមពល សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ដែលស្ថិតនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ តាមសំណើសុំរបស់ក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការចេញអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារនៃសេចក្តីព្រាងលក្ខខណ្ឌអាជ្ញាបណ្ណដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងលក្ខខណ្ឌអាជ្ញាបណ្ណនៅ ........................................ ........................................................................................................ សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះសូមសាធារណជនរស់នៅក្នុងភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញអាជ្ញាបណ្ណឲ្យក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** " ។៚

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ទី នរិន្ទ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

សេចក្តីព្រាង

អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# អាជ្ញាបណ្ណចែកចាយ

# សម្រាប់ធ្វើសេវាកម្មចែកចាយអគ្គិសនីនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសប៉ោយប៉ែត ស្ថិតនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

# DISTRIBUTION LICENSE

# FOR PROVIDING ELECTRIC POWER DISTRIBUTION SERVICE AT POI PET SPECIAL ECONOMY ZONE LOCATED AT SANGKAT PHSAR KANDAL, KRONG POI PET, BANTEAY MEANCHEY PROVINCE

ក្រុមហ៊ុន ប៉ោយប៉ែត ភីភីអេសអ៊ីហ្សិត

POI PET PP SEZ CO., LTD

ថ្ងៃទី ខែ ឆ្នាំ២០១៧

..., 2017

# ផ្នែកទី១
# សេចក្ដីសម្រេចផ្ដល់សិទ្ធិឲ្យធ្វើសេវាកម្ម

## PART I

## DECISION TO GRANT THE RIGHT TO PROVIDE THE ELECTRIC POWER SERVICE